# ភាពមានសិទ្ធិទទួលបានការផ្តល់សិទ្ធិអនុញ្ញាត

អ្នកទទួលត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងអស់៖

- ក្លាយជាអតិថិជនដែលមានសិទ្ធិទទួលបាន DDA នៅក្នុង RCW 71A.10.020(5).
- មានពិការភាពសមស្របតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងច្បាប់ស្តីពីការធានារ៉ាប់រងសង្គមកិច្ច។
- ដាក់ពាក្យសុំសេវាកម្មថែទាំសុខភាព/កម្មវិធី Medicaid រយៈពេលវែង និងបានបញ្ជាក់ប្រាក់ចំណូលដែលមិនលើសពី 300% នៃបទដ្ឋានស្តីពីការធានារ៉ាប់រងសហព័ន្ធ SSI .
  - ប្រសិនបើកូនម្នាក់ដែលមានប្រាក់ចំណូលនិងធនធានរបស់ឪពុកឬម្តាយមិនត្រូវបានគិត។
  - ប្រសិនបើមនុស្សពេញវ័យម្នាក់ដែលរស់នៅជាមួយប្តីឬប្រពន្ធប្រាក់ចំណូលនិងធនធានរបស់ប្តីឬប្រពន្ធ មិនត្រូវបានគិត។
- មានធនធានតិចជាង $2,000 ដុល្លារ ឬស្ថិតនៅក្នុងកម្មវិធីសុខភាព Apple Health សម្រាប់កម្មករដែលមានកម្មវិធីពិការភាព (HWD).
- បំពេញតាមកម្រិតនៃការថែទាំសុខភាពដែលបានផ្តល់ជូននៅមណ្ឌលថែទាំសុខភាពកម្រិតមធ្យមសម្រាប់បុគ្គលដែលមានពិការភាពខាងបញ្ញាដូចដែលបានកំណត់តាមការវាយតម្លៃ DDA.
- ផែនការសេវាកម្មផ្តោតលើបុគ្គល បង្ហាញពីរបៀបដែលតម្រូវការសុខភាព សុវត្ថិភាព និងការធ្វើឱ្យមានទីតិសម្បទា អាចឆ្លើយតបនៅក្នុងសហគមន៍ដែលមានសេវាកម្ម និង/ឬ ការត្រួតពិនិត្យដែលមានសិទ្ធិអនុញ្ញាតប្រចាំខែ។
- យល់ព្រមទទួលយកសេវាកម្មនៅតាមផ្ទះនិងសហគមន៍ជាជាង ICF/IID.



# ទទួលបានការផ្តល់សិទ្ធិអនុញ្ញាត

ការស្នើសុំចុះឈ្មោះ ឬដើម្បីផ្លាស់ប្តូរទៅជាការផ្តល់សិទ្ធិអនុញ្ញាតដែលមានជម្រើសអាចធ្វើបានគ្រប់ពេល។ សូមសាកសួរប្រធានគ្រប់គ្រងធនធានករណីសំណុំរឿង។ ប្រសិនបើ CRM មិនអាចមាន សូមទុកសារមួយនៅលើបណ្តាញសេវាកម្មមិនគិតថ្លៃនៅមូលដ្ឋានដែលមានរាយបញ្ជីនៅការិយាល័យប្រចាំតំបន់ ឬបញ្ជូនសំណើតាមអនឡាញតាម www.dshs.wa.gov/dda/service-and-information-request។ ការបំពេញតាមលក្ខណៈវិនិច្ឆ័យសេវាកម្មចំពោះការផ្តល់សិទ្ធិអនុញ្ញាតនេះ មិនធានាការចូលប្រើសេវាកម្មឡើយ។ ការផ្តល់សិទ្ធិអនុញ្ញាតនីមួយៗមានកំណត់ចំពោះមនុស្សដែលអាចបម្រើសេវាជូនបាន។ DDA មានសិទ្ធិកំណត់ការចុះឈ្មោះដោយផ្អែកលើលទ្ធភាពនៃការផ្តល់ថវិកាសម្រាប់អ្នកចូលរួមផ្តល់សិទ្ធិអនុញ្ញាតថ្មី។

# សិទ្ធិសវនាការរដ្ឋបាល

បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានសវនាការរដ្ឋបាលដោយមានការសម្រេចចិត្តណាមួយដូចខាងក្រោម ដោយមិនគិតពីកម្មវិធីឬសេវាកម្ម៖

- ភាពមានសិទ្ធិទទួលបាន DDA ត្រូវបានបដិសេធ បញ្ឈប់ ឬ DDA បានពន្យារពេលដោយមិនសមហេតុផលលើការដាក់ពាក្យសុំ ឬ
- ប្រភេទឬចំនួនសេវាកម្មដែលមិនបានអនុញ្ញាតឱ្យទទួល ឬ
- ការបដិសេធ ការកាត់បន្ថយ ឬការបញ្ចប់សេវាកម្ម ឬ
- ការបដិសេធជម្រើសនៃអ្នកផ្តល់សេវាកម្ម ឬ
- ប្រសិនបើបានផ្លាស់ប្តូរទៅការកំណត់កន្លែងរស់នៅផ្សេងគ្នាមិនមែនជាជម្រើសមួយទេ ឬ
- ការបដិសេធ DDA មិនគោរពតាមការស្នើសុំមិនឱ្យផ្ញើលិខិតជូនដំណឹងទៅបុគ្គលណាម្នាក់ផ្សេងទៀត ឬ
- ការដកឈ្មោះចេញពីកម្មវិធីផ្តល់សិទ្ធិអនុញ្ញាត ឬ
- ការបដិសេធចំពោះសំណើ ដើម្បីទទួលបានសេវាកម្ម ICF/IID ដោយជំនួសឱ្យសេវាកម្មផ្តល់សិទ្ធិអនុញ្ញាត ឬ
- DDA សម្រេចថាសេវាកម្មដែលអាចមានតាមការផ្តល់សិទ្ធិអនុញ្ញាតនាពេលបច្ចុប្បន្នអាចបំពេញតាមតម្រូវការសុខភាពនិងសុខុមាលភាព ហើយបុគ្គលមិនយល់ព្រម ឬ
- បុគ្គលម្នាក់ត្រូវបានគេវាយតម្លៃថាមិនត្រូវការកម្រិតថែទាំសុខភាព ICF/IID ទេ។




សូមជួបយើងតាមអនឡាញតាម៖
*dshs.wa.gov/dda/service-and-information-request*

ស្វែងរកការិយាល័យតាម៖
*dshs.wa.gov/office-locations*

សូមហៅទូរស័ព្ទមកយើងខ្ញុំ ៖

| ខោនធី | ទូរស័ព្ទនិងអ៊ីម៉ែល |
|---|---|
| Chelan, Douglas, Ferry, Grant, Lincoln, Okanogan, Pend Oreille, Spokane, Stevens | (800) 319-7116<br>R1ServiceRequestA@dshs.wa.gov |
| Adams, Asotin, Benton, Columbia, Franklin, Garfield, Kittitas, Klickitat, Walla Walla, Whitman, Yakima | (866) 715-3646<br>R1ServiceRequestB@dshs.wa.gov |
| Island, San Juan, Skagit, Snohomish, Whatcom | (800) 567-5582<br>R2ServiceRequestA@dshs.wa.gov |
| King | (800) 974-4428<br>R2ServiceRequestB@dshs.wa.gov |
| Kitsap, Pierce | (800) 735-6740<br>R3ServiceRequestA@dshs.wa.gov |
| Clallam, Clark, Cowlitz, Grays Harbor, Jefferson, Lewis, Mason, Pacific, Skamania, Thurston, Wahkiakum | (888) 707-1202<br>R3ServiceRequestB@dshs.wa.gov |

*ប្រជាពលរដ្ឋដែលត្រូវការការគាំទ្រដោយមានការស្តាប់ឬការប្រាស្រ័យទាក់ទងអាចហៅទូរស័ព្ទមកសេវាកម្មបញ្ជូនបន្តតាមទូរគមនាគមន៍រដ្ឋវ៉ាស៊ីនតោន (Washington Telecommunication Relay Service) ដោយចុចលេខ 7-1-1 ឬ 1-800-833-6388 (TTY)។*

Washington State
Department of Social & Health Services
*Transforming lives*

DSHS 22-1754 CA (Rev. 10/20) Cambodian

# ការផ្តល់សិទ្ធិអនុញ្ញាត (Basic Plus Waiver)

ពីផ្នែករដ្ឋបាលអភិវឌ្ឍន៍ពិការ



Washington State
Department of Social & Health Services
*Transforming lives*

# ទិដ្ឋភាពទូទៅនៃការផ្តល់សិទ្ធិអនុញ្ញាត

ផ្នែករដ្ឋបាលអភិវឌ្ឍជនពិការនៃក្រសួងសេវាកម្មសង្គមកិច្ចនិងសុខាភិបាល មានកម្មវិធីផ្តល់សិទ្ធិអនុញ្ញាតកម្មវិធីដេឌីឃេត Medicaid តាមសហគមន៍ និងតាមផ្ទះចំនួនប្រាំ។ ការផ្តល់សិទ្ធិអនុញ្ញាតនីមួយៗ ផ្តល់ជូនសេវាកម្មជាក់លាក់ ដើម្បីបំពេញតាមតម្រូវការសុខភាពនិងសុវត្ថិភាពនៅសហគមន៍។ ការផ្តល់សិទ្ធិអនុញ្ញាត (Basic Plus Waiver) ផ្តល់ជូនសេវាកម្មផ្សេងៗគ្នាជាច្រើន ដែកមិនអាចមានតាមរយៈធនធានផ្សេងទៀត (ការធានារ៉ាប់រងឯកជន, កម្មវិធីមេឌីឃេត Medicaid, សាលារៀន ជាដើម)

ការផ្តល់សិទ្ធិអនុញ្ញាត (Basic Plus waiver) គាំទ្របុគ្គលនានាដែលតម្រូវឱ្យមានសេវាកម្មដែលមានសិទ្ធិអនុញ្ញាត ដើម្បីបំពេញតាមតម្រូវការសុខភាពនិងសុវត្ថិភាពដែលបានវាយតម្លៃនៅសហគមន៍។ សេវាកម្មនានាត្រូវបានផ្តល់ជូននៅផ្ទះរបស់ពួកគេផ្ទាល់ ផ្ទះគ្រួសារនៅផ្ទះគ្រួសារមនុស្សពេញវ័យ ឬមជ្ឈមណ្ឌលលំនៅដ្ឋានមនុស្សពេញវ័យ។ ការផ្តល់សិទ្ធិអនុញ្ញាត (Basic Plus waiver) បម្រើសេវាកម្មដល់បុគ្គលគ្រប់វ័យទាំងអស់។

ប្រសិនបើតម្រូវការវាយតម្លៃសេវាកម្មនានាដែលលើសវិសាលភាពនៃសេវាកម្មដែលបានផ្តល់ជូនក្រោម ការផ្តល់សិទ្ធិអនុញ្ញាត (Basic Plus waiver) នោះ DDA នឹងខំប្រឹងប្រែងខាងក្រោមមួយឬច្រើន ដើម្បីបំពេញតាមតម្រូវការសុខភាពនិងសុខុមាលភាព។

- ការកំណត់ការគាំទ្រធម្មតាដែលអាចមានច្រើនថែមទៀត;
- ផ្តួចផ្តើមការលើកលែង ដើម្បីគ្រប់គ្រងការទទួលសេវាកម្មដែលអាចមានសេវាកម្មដែលមិនមានសិទ្ធិអនុញ្ញាតមិនត្រូវបានរាប់បញ្ចូលក្នុងការផ្តល់សិទ្ធិអនុញ្ញាត (Basic Plus waiver) ក្រៅពីការគាំទ្រធម្មតា។
- ផ្តល់ពាក្យសុំសម្រាប់ការផ្តល់សិទ្ធិអនុញ្ញាតជំនួសដែលសេវាកម្មត្រូវការ
- ផ្តល់ជូនការកំណត់នៅក្នុង ICF/IID.

ប្រសិនបើគ្មានជម្រើសខាងលើបំពេញតម្រូវការសុខភាពនិងសុខុមាលភាពបានទេ DDA អាចបញ្ចប់ភាពមានសិទ្ធិទទួលការផ្តល់សិទ្ធិអនុញ្ញាត។ ប្រសិនបើត្រូវបានបញ្ឈប់ពីការផ្តល់សិទ្ធិអនុញ្ញាត បុគ្គលម្នាក់អាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់សេវាកម្ម DDA មិនមានសិទ្ធិអនុញ្ញាតផ្សេងទៀត។

# សេវាកម្មដែលមានសិទ្ធិអនុញ្ញាត

ប្រើខិត្តប័ណ្ណនេះ ដើម្បីរៀបចំផែនការវាយតម្លៃប្រចាំឆ្នាំ។ ប្រធានគ្រប់គ្រងធនធានករណីសំណុំរឿងនឹងពន្យល់ពីសេវាកម្មនិងតម្រូវការទាមទារ និងឯកសារដែលបានជ្រើសរើសក្នុងផែនការសេវាកម្មផ្តោតលើបុគ្គល។ សេវាកម្មខ្លះទាមទារការពិនិត្យឡើងវិញនិងការអនុម័តមុនពេលសេវាកម្មត្រូវបានបញ្ជូន។ សាកសួរ CRM អំពីព័ត៌មានអ្វីខ្លះ ដែលត្រូវការសម្រាប់ការអនុម័តជាមុន។ សេវាកម្មមានបួនប្រភេទដែលមានអាយុកំណត់ រួមមាន៖

- ***សេវាកម្មសហគមន៍*** - លើកកម្ពស់ការចូលរួមរបស់អតិថិជន និងការធ្វើសមាហរណកម្មនៅក្នុងសហគមន៍
- ***សេវាកម្មអ្នកជំនាញវិជ្ជាជីវៈ*** - សេវាកម្មគាំទ្រដែលផ្តល់ដោយអ្នកជំនាញវិជ្ជាជីវៈដែលមានកិច្ចសន្យា
- ***សេវាកម្មថែទាំសុខភាព*** - គាំទ្រដល់អ្នកចូលរួមនិងអ្នកថែទាំរបស់ពួកគេ
- ***ទំនិញនិងសេវាកម្ម*** - ឧបករណ៍ ការផ្គត់ផ្គង់ និងសេវាកម្មជំនាញសម្រាប់អ្នកចូលរួម

***ប្រើប្រអប់ធីក ដើម្បីបង្ហាញ CRM ថាសេវាកម្មណាមួយដែលចាប់អារម្មណ៍ ៖***

## សេវាកម្មសហគមន៍

☐ **ការចូលរួមរបស់សហគមន៍** - គាំទ្របង្កើនការតភ្ជាប់និងការចូលរួមធនធានសហគមន៍។

☐ **ការដាក់បញ្ចូលសហគមន៍** - សេវាកម្មគាំទ្រជាលក្ខណៈបុគ្គលដែលភ្ជាប់ប្រជាពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋានរបស់ពួកគេ ដើម្បីពង្រឹងទំនាក់ទំនងជាមួយអ្នកដទៃដែលមានចំណាប់អារម្មណ៍ស្រដៀងគ្នា។

☐ **ការងារដែលមានការគាំទ្រ** - ការគាំទ្របុគ្គលនិងក្រុមដែលមានដំណើរការជាបន្តយ៉ាងខ្លាំង ដើម្បីទទួលបាននិងរក្សាការងារ។ *21+*

☐ **មធ្យោបាយដឹកជញ្ជូន** - ការផ្តល់សំណងដល់អ្នកផ្តល់សម្រាប់ដឹកជញ្ជូនដែលមិនមែនជាវេជ្ជសាស្ត្រ ដែលតម្រូវឱ្យមានដើម្បីទទួលបានសេវាកម្មដែលមានសិទ្ធិអនុញ្ញាត ដែលបានបញ្ជាក់ក្នុង PCSP ។

## សេវាកម្មជំនាញវិជ្ជាជីវៈ

☐ **សេវាកម្មស្ថេរភាព** - ជំនួយនិងការគាំទ្រនៅអំឡុងពេលមានវិបត្តិសុខភាពផ្លូវចិត្ត។ សេវាកម្មរួមមានការធ្វើឱ្យមាននីតិវិធីសម្បទាតាមជំនាញ ការពិគ្រោះយោបល់បុគ្គលិក/ក្រុមគ្រួសារ និងសេវាកម្មកន្លែងសម្រាកផ្លាស់ប្តូរវិបត្តិ។

☐ **ការគាំទ្រ និងការពិគ្រោះយោបល់ផ្លូវចិត្តដែលមានសង្ឃឹម** - គាំទ្រដល់ការវាយតម្លៃនិងដោះស្រាយតម្រូវការសុខភាពផ្លូវចិត្ត។ ចំណុចទាំងនេះ រួមមានការធ្វើអន្តរាគមន៍ដើម្បីលើកកម្ពស់ដែលលើកកម្ពស់ផ្លូវចិត្តធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិត និងការបញ្ចូលក្នុងសហគមន៍។ *0-20*

☐ **ការប៉ាន់ប្រមាណហានិភ័យ** - ការវាយតម្លៃអំពីអាកប្បកិរិយាហឹង្សា ការឈ្លបចាប់អំពើហឹង្សាផ្លូវភេទ ឬអាកប្បកិរិយាដែលហួសប្រមាណដើម្បីកំណត់ពីតម្រូវសម្រាប់សេវាកម្មផ្លូវចិត្ត វេជ្ជសាស្ត្រ ឬព្យាបាល។

☐ **ការធ្វើឱ្យមាននីតិសម្បទាតាមជំនាញ** - ការគាំទ្រជាលក្ខណៈបុគ្គលដើម្បីស្វែងយល់ ឬថែរក្សាជំនាញជីវិតរស់នៅទូលំទូលាយ។

☐ **ការពិគ្រោះយោបល់បុគ្គលិក/គ្រួសារ** - ការពិគ្រោះយោបល់ជំនាញវិជ្ជាជីវៈដល់ក្រុមគ្រួសារនិងអ្នកផ្តល់សេវាកម្មដោយផ្ទាល់ ដើម្បីបំពេញតម្រូវការបុគ្គលកាន់តែប្រសើរ។ ការពិគ្រោះយោបល់ដែលអាចមាន។

☐ **ការព្យាបាល** - សេវាកម្មព្យាបាលដោយឱ្យអ្នកជំងឺធ្វើសកម្មភាពផ្សេងៗ ផ្នែករាងកាយ និងការនិយាយ ភាសា និងសេវាកម្មស្តាប់លើសពីអ្វីផ្តល់ដោយកម្មវិធីមេឌីឃេត Medicaid (Apple Health). *21+*

## សេវាកម្មថែទាំសុខភាព

☐ **ពេលសម្រាក** - ការផ្តល់ជំនួយរយៈពេលខ្លីដល់បុគ្គលម្នាក់ៗដែលរស់នៅនិងការមើលថែទាំសុខភាពអតិថិជន។

☐ **ជំនាញថែទាំ** - សេវាកម្មរយៈពេលដែលមានជំងឺរាំរ៉ៃ ដើម្បីដោះស្រាយតម្រូវការមិនបានបំពេញតាមរយៈ កម្មវិធីមេឌីឃេត Medicaid (Apple Care). *21+*

## ទំនិញនិងសេវាកម្ម

☐ **ការសម្ងាប់សង្កើច** - ការព្យាបាលសង្កើចនៅក្នុងផ្ទះ។

☐ **ការសម្របសម្រួលផ្នែកព្យាបាល** - ការកែសម្រួលបរិយាកាសផ្ទះដើម្បីកាត់បន្ថយឬបំបាត់ស្ត្រេស។

☐ **ការសម្របសម្រួលផ្នែកបរិស្ថាន** - ការកែសម្រួលរាងកាយទៅនឹងផ្ទះដែលចាំបាច់សម្រាប់បុគ្គលម្នាក់ដើម្បីបន្តរស់នៅក្នុងសហគមន៍។

☐ **គ្រឿងបរិក្ខារនិងការផ្គត់ផ្គង់ដែលមានជំនាញ** - ឧបករណ៍ចាំបាច់និងការផ្គត់ផ្គង់ដែលមិនអាចមាននៅក្រោមកម្មវិធីមេឌីឃេត Medicaid (Apple Care) ដែលរួមទាំងឧបករណ៍និងការផ្គត់ផ្គង់ដែលត្រូវការដើម្បីអនុវត្តន៍ផែនការគាំទ្រផ្លូវចិត្តដែលមានសង្ឃឹមឬព្យាបាល។

☐ **ការអប់រំសុខភាព** - លិខិតដែលបោះពុម្ពផ្សាយជាលក្ខណៈបុគ្គលរៀងរាល់ខែ ដែលរៀបចំឡើងដើម្បីជួយគ្រប់គ្រងបញ្ហាទាក់ទងសុខភាពនិងការសម្រេចគោលដៅសុខភាព។